ការប៉ះពាល់ដល់ច្បាប់រដ្ឋធម្មនុញ្ញទៀតផង ។ មាត្រាដែលមានចម្រូងចម្រាស់ជាងគេនេះ គឺមាត្រា៥ ដែលចែងថា " តំណាងរាស្ត្រមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កត្តិយសរបស់បុគ្គលដ៏ទៃ ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។"

អ្នកតំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជា ដែលជាអ្នកការពារច្បាប់ម្នាក់ក្នុងសម័យប្រជុំនោះ បានពន្យល់ថា *"ច្បាប់នេះតាក់តែងឡើងដើម្បីផលប្រយោជន៍តំណាងរាស្ត្រផង និងផលប្រយោជន៍ប្រជាពលរដ្ឋផង ។ តំណាងរាស្ត្រមិនត្រូវឆ្លៀតឱកាសប្រើអភ័យឯកសិទ្ធិរបស់ខ្លួនដើម្បីធ្វើតាមទំនើងចិត្ត និងបង្កអសន្តិសុខ ព្រមទាំងភាពវឹកវរឡើយ ។"*

ប៉ុន្តែ ក្រុមអ្នកតំណាងរាស្ត្រគណបក្សជំទាស់បានលើកឡើងថា មាត្រា៥នេះមានគោលបំណងចង់បំបិទមាត់អ្នកប្រឆាំង ប៉ុន្តែវាបង្ហាញពីការដើរថយក្រោយនៃតួនាទីរបស់អ្នកតំណាងរាស្ត្រក្នុងរបបសភានិយម ។ អ្នកតំណាងរាស្ត្រ **កែវ រ៉េមី** ដែលជាអ្នកតំណាងរាស្ត្រតែមួយគត់ដែលមិនបានអនុម័តច្បាប់នេះនៅក្នុងអង្គប្រជុំ បានបង្ហាញទស្សនៈថា *"ច្បាប់នេះកំរិតសិទ្ធិអ្នកតំណាងរាស្ត្រ ។ គ្មានការចែងឱ្យច្បាស់លាស់អំពីសញ្ញាណនៃសណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិឡើយ ។ ហេតុនេះតំណាងរាស្ត្រមានការស្ទាក់ស្ទើរនឹងការធ្វើការតវ៉ាជាមួយប្រជាពលរដ្ឋ ។"*

ពាក់ព័ន្ធនឹងការពិភាក្សាលើបញ្ហាការដកអភ័យឯកសិទ្ធិសភា អ្នកតំណាងរាស្ត្រ**ម៉ោញ សាផាន** មកពីគណបក្សហ៊្វុនស៊ិនប៉ិច បានធ្វើការគាំទ្រមតិយោបល់ ភាគ-ច្រើនរបស់អ្នកតំណាងរាស្ត្រគណបក្សជំទាស់ ដែលចង់ឱ្យរដ្ឋសភាគួរតែបង្កើតគណៈកម្មការពិសេសមួយសំរាប់ធ្វើការស៊ើបអង្កេតបន្ថែមលើរាល់សំណើរបស់តុលាការ ឬក្រសួងយុត្តិធម៌ ដែលស្នើមកដើម្បីសុំលើកអភ័យឯកសិទ្ធិ ថាតើសំណើទាំងនោះត្រឹមត្រូវ ឬអត់ ព្រោះអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រមានសារៈសំខាន់ណាស់ ។

អ្នកសង្កេតការណ៍ឯករាជ្យមួយចំនួនបានអះអាងថា វិធានការច្បាប់ដែលមានសំរាប់ដាក់ឱ្យអនុវត្តពីមុន គឺមិនគ្រប់គ្រាន់ឡើយសំរាប់ការលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រក្នុងពេលកន្លងមក ។ គឺដោយហេតុនេះហើយ ទើបគេចង់ឱ្យអនុម័តសេចក្តីស្នើច្បាប់នេះ ដែលនិយាយអំពីការលើកអភ័យឯកសិទ្ធិ និងការប្រជុំសំងាត់ ។ ទោះបីជាយ៉ាងណាក៏ដោយ មានការយល់ឃើញថា ការប្រជុំនានារបស់សភាសំរាប់ការលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ គឺជារឿងមួយសំខាន់ខ្លាំងណាស់ ដែលចាំ-បាច់គួរតែបើកចំហឱ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតគ្រប់រូបមានសិទ្ធិបានដឹង បានឮ ព្រោះជាការដកតំណាងដែលប្រជាពលរដ្ឋរាប់ម៉ឺននាក់ជាអ្នកបោះឆ្នោតជូន ។

ស្របជាមួយគ្នានោះ ក៏មានការសំដែងភាពព្រួយបារម្ភជាខ្លាំងផងដែរចំពោះបញ្ហានេះ ពីសំណាក់សហគមន៍អន្តរជាតិនានា ។ អ្នកតំណាងរាស្ត្រសភាអឺរ៉ុប លោក **ម៉ាកកូ ពេនណូឡា** បានសំដែងនូវប្រតិកម្មខ្លាំងៗក្នុងសារព័ត៌មាននានា ជំទាស់នឹងច្បាប់នេះថា *"ច្បាប់នេះមានលក្ខណៈចំលែកក្នុងបណ្ដាជួររដ្ឋសភា ។ ច្បាប់នេះច្រានចោលនូវអ្វីដែលជាតំណាងរាស្ត្រ ។ ហើយច្បាប់នេះក៏នឹងធ្វើឱ្យកម្ពុជាឈានទៅរករបបផ្ដាច់ការ និងបំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិប្រឆាំង ។"* លោក **ចូសេហ្វ ម៉ូសូម៉េលី** ឯកអគ្គរដ្ឋទូតអាមេរិចប្រចាំនៅប្រទេសកម្ពុជាបានចេញសេចក្តីថ្លែងការណ៍មួយតាមអ៊ីម៉ែលថា *" នេះប្រហែលជាការកើតលើកដំបូងនៃការក្រៀវខ្លួនឯងជាសមូហភាព ។ ប្រការដែលពួកគេសុខចិត្តលះបង់សេរីភាពរបស់ពួកគេ... ។ ច្បាស់ណាស់ថាច្បាប់នេះនឹងដាក់សភានេះនៅដោយឡែកពីសភាដទៃទៀតសឹងតែទាំងអស់ ។"*

## ការអនុម័តច្បាប់ស្ដីពីឯកពន្ធភាពដែលខ្វះការគាំទ្រ

ការដាក់ទណ្ឌកម្មជាប់ពន្ធនាគារ និងផាកពិន័យជាប្រាក់ចំពោះសម័ន្ធភាពស្នេហាក្រៅចំណងអាពាហ៍ពិពាហ៍ (រួមមាន ទ្វេពន្ធភាព ស្នន់ និងផិតក្បត់) ដែលមានចែងក្នុងសេចក្តីស្នើច្បាប់ឯកពន្ធភាព បានធ្វើឱ្យមានការជជែកពិភាក្សាយ៉ាងតានតឹងរវាងអ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំសភា នាថ្ងៃទី៣១ សីហា និងថ្ងៃទី១ កញ្ញា ឆ្នាំ២០០៦ កន្លងទៅ ។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានគាំទ្រយ៉ាងពេញទំហឹង និងការពារសេចក្តីស្នើច្បាប់នោះថា នេះជាវិធានការទប់ស្កាត់បន្ទាន់មួយចំពោះសុខដុមរមនាក្នុងគ្រួសារខ្មែរ ដែលត្រូវបានគំរាមកំហែងពីអំពើផិតក្បត់ ។ ផ្ទុយទៅវិញ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច ជំទាស់យ៉ាងពេញទំហឹង រហូតដល់មានអ្នកតំណាងរាស្ត្រមួយចំនួនដើរចេញពីសម័យប្រជុំសភាមិនបាននៅអនុម័ត ។

សេចក្តីស្នើច្បាប់ស្ដីពីឯកពន្ធភាពនេះ ត្រូវបានតាក់តែងឡើងដោយសមាជិកសភា ព្រឹទ្ធសភា និងភរិយារបស់មន្ត្រីជាន់ខ្ពស់មួយចំនួន មកពីគណបក្សប្រជាជន-កម្ពុជា សរុប៦៣រូប តាំងពីដើមខែកុម្ភៈ ឆ្នាំ២០០៦ កន្លងទៅ ។ ការអនុម័តក្នុងសម័យប្រជុំសភា ត្រូវបានធ្វើឡើងដោយសំលេង៦៤ ក្នុងចំណោមកូរ៉ុមសរុប៦៩ ក្រោយពីការជជែកពិភាក្សាយ៉ាងតានតឹង ។

ក្រុមអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានការពារយ៉ាងស្វិតស្វាញក្នុងសម័យប្រជុំថា ការបង្កើតច្បាប់នេះគឺក្នុងគោលបំណងពង្រឹងសីលធម៌ សុភមង្គលក្នុងគ្រួសារ និងប្រពៃណីខ្មែរ ព្រមទាំងបំពេញបន្ថែមលើធម្មនុញ្ញមាត្រា៤៥ និងជួយទប់ស្កាត់ផងដែរនូវអំពើពុករលួយ ។ អ្នកតំណាងរាស្ត្រ **ឃួន សុដារី** បានលើកឡើងថា *"សេចក្តីស្នើច្បាប់នេះមានសារៈសំខាន់ ហើយវាបានឆ្លើយតបទៅនឹងសភាពការជាក់ស្តែងក្នុងប្រទេស វាមិនមែនជាការជ្រួលច្របល់តាមគ្នានោះទេ ។ ខ្ញុំគាំទ្រព្រោះបញ្ហានេះវាមិនមែនតែជាបញ្ហាក្នុងគ្រួសារទេវាជាបញ្ហារបស់ជាតិទាំងមូល ។ "* ចំណែកអ្នកតំណាងរាស្ត្រ **ជាម យៀប** គាំទ្រថា *"ច្បាប់នេះនឹងអាចជួយកាត់បន្ថយអំពើជួញដូរលើស្ត្រី និងការផិតក្បត់ ។"*

ចំណែកអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីយល់ថាសេចក្តីស្នើច្បាប់នេះមានភាពល្បិចកិច្ចកល និងលូកលាន់ជ្រុលហួសហេតុចូលបញ្ហាឯកជន ព្រមទាំងប្រមើល

មើលថា ការអនុវត្តនឹងពុំមានប្រសិទ្ធិភាពអ្វីឡើយ។ អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** លើកឡើងថា *"ច្បាប់នេះមានលក្ខណៈរើសអើង ជ្រុលនិយម និងដើរថយក្រោយ។ យើងគួរតែទុកឱ្យសង្គមវាយតំលៃទៅលើសីលធម៌សង្គម។ បញ្ហាមនោសញ្ចេតនាក្នុងគ្រួសារ យើងមិនគួរអនុញ្ញាតឱ្យអ្នកខាងក្រៅទៅលូកលាន់ទេ វាអាចនាំឱ្យគ្រួសារនេះនឹងមានបញ្ហាកាន់តែធំទៅវិញ។ ច្បាប់នេះហាក់ដូចជារើសអើងចំពោះកុមារទៅវិញ ព្រោះឪពុកម្តាយរបស់ខ្លួនមានការចោទប្រកាន់គ្នា និងឈានទៅជាប់ពន្ធនាគារព្រោះតែរឿងផឹតក្បត់ នាំឱ្យពួកគេមានភាពខ្មាស់អៀន នឹងរើសអើងពីអ្នកនៅជុំវិញខ្លួន។ ,...នៅពេលប្តីនោះចេញពីពន្ធនាគារហើយ តើប្តីនេះអាចយកប្រពន្ធនោះបានវិញទេ?... ខ្ញុំយល់ថាគាត់មិនយកបានទេ។ ដូច្នេះអត្រាលែងលះកាន់តែកើនឡើងទៅវិញ។ សេចក្តីស្នើច្បាប់នេះមិនមានសារៈសំខាន់ទេ យើងគួរតែគិតអំពីច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់ព្រហ្មទណ្ឌជាដើមវិញទើបសំខាន់។"* អ្នកតំណាងរាស្ត្រ **កែវ រ៉េមី** លើកឡើងថា *"គាំទ្រយោបល់របស់លោកជំទាវ កែ សុវណ្ណរតន៍ ដែលមិនជ្រួលច្របល់តាមគ្នា មិនមែនរាជរដ្ឋាភិបាល និងរដ្ឋសភារវល់តែរឿងដីមួយចបកាប់នោះទេ។ ច្បាប់សំខាន់ៗកន្លងមក យើងអនុវត្តមិនទាន់បានល្អនៅឡើយ ដូច្នេះយើងត្រូវយកពេលវេលាទៅគិតគូរថាត្រូវធ្វើដូចម្តេចក្នុងការអនុវត្តច្បាប់សំខាន់ៗទាំងនោះឱ្យបានល្អ ប្រសើរជាង។"*

ចំណែកអ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន** មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច យល់ឃើញថា ច្បាប់នេះពុំមានសារៈសំខាន់ទេ ព្រោះប្រទេសមានច្បាប់អាពាហ៍ពិពាហ៍រួចហើយ ព្រមទាំងមានច្បាប់ធម្មនុញ្ញថែងពីប្តីមួយប្រពន្ធមួយទៀតផង។

ចំពោះមតិអង្គការសង្គមស៊ីវិលវិញ គាំទ្រឱ្យមានច្បាប់ឯកពន្ធភាព តែមិនគាំទ្រឱ្យមានការដាក់ទោសព្រហ្មទណ្ឌទៅលើបញ្ហាចំណងស្នេហាក្រៅអាពាហ៍ពិពាហ៍នេះឡើយ ដោយយល់ឃើញថា ការយកច្បាប់ព្រហ្មទណ្ឌមកដាក់ក្នុងច្បាប់នេះ ធ្វើឱ្យច្បាប់មានលក្ខណៈចាស់គំរិល ដែលអរិយប្រទេសសព្វថ្ងៃគេលែងយកមកប្រើប្រាស់យូរហើយ។ អ្នកសង្កេតការណ៍ អ្នកជំនាញការច្បាប់ ព្រមទាំងអង្គការមួយចំនួនដែលបានធ្វើការងារលើបញ្ហាស្ត្រី យល់ឃើញថា ប្រសិនបើច្បាប់នេះត្រូវបានគេពង្រឹងឱ្យបានម៉ត់ចត់ក្នុងការអនុវត្តនោះ វានឹងមានផលប៉ះពាល់ជាច្រើនដល់សង្គម ដោយនឹងធ្វើឱ្យអត្រានៃការសម្រេចលែងលះគ្នារបស់ប្តីប្រពន្ធកាន់តែច្រើនឡើងទៅវិញ និងអត្រានៃការចុះសំបុត្រអាពាហ៍ពិពាហ៍ក៏នឹងមានការថយចុះផងដែរ។ អ្នកស្រី **អ៊ុង ចាន់ថុល** នាយកអង្គការដើម្បីជួយស្ត្រីមានវិបត្តិ បានលើកឡើងពីចំណុចវិជ្ជមានមួយចំនួនរបស់ច្បាប់ថា *"ច្បាប់នេះជួយដល់ស្ត្រីព្រោះស្រុកខ្មែរសំបូរបុរសមិនស្មោះ។ វាជួយឱ្យមានសាមគ្គីភាពក្នុងគ្រួសារ កាត់បន្ថយជំងឺផ្សេងៗ និងការជួញដូរស្ត្រីផងដែរ។ ,..ខ្ញុំធ្វើការជាមួយស្ត្រីជាង១០០០នាក់ដែលបែកបាក់គ្រួសារ ក្នុងនោះមាន៥០%ដោយសារភាពមិនស្មោះត្រង់របស់ប្តី។"* តែអ្នកស្រីក៏បានយល់ឃើញផងដែរថា ការអនុវត្តប្រហែលជាបានតែចំពោះអ្នកក្រប៉ុណ្ណោះ វាមិនអាចអនុវត្តចំពោះអ្នកមានប្រាក់មានអំណាចបានទេ។" លោក **អ៊ុក វ៉ាន់ដេត** មេធាវីនៃអង្គការជំនួយផ្នែកច្បាប់កម្ពុជា បានអះអាងថា *"វានឹងធ្វើឱ្យការលែងលះគ្នាកាន់តែកើនច្រើនទៅវិញ។,.. ជំរុញឱ្យប្តីប្រពន្ធមិននាំគ្នាទៅចុះអេតាស៊ីវិល ស្ត្រី និងកុមារកំព្រាពុំមានអ្នកចិញ្ចឹមពេលមានការលែងលះគ្នា។"*

## ការសង្កេតលើបេសកកម្មរបស់អ្នកតំណាងរាស្ត្រចុះទៅកាន់មណ្ឌលនានា




អ្នកតំណាងរាស្ត្រចំនួន៦៨រូបបានចុះបេសកកម្មទៅកាន់មណ្ឌលរបស់ខ្លួន និងមណ្ឌលដទៃទៀត ដែលក្នុងនោះមាន ២០រូបមកពីគណបក្សសមរង្ស៊ី (ស្មើនឹង៨៣%នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់) ៤២រូបមកពីគណបក្សប្រជាជនកម្ពុជា (ស្មើនឹង៥៨% នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់) និង៦រូបមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច (ស្មើនឹង២៣% នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់)។

អ្នកតំណាងរាស្ត្រទាំង**៦៨រូប**បានចុះបេសកកម្មចំនួន**២១៥លើក** ដែលមានការកើនឡើងជាង **៥%** បើធៀបទៅនឹងខែកក្កដាកន្លងទៅដែលពេលនោះមានតែ**២០៧**បេសកកម្មអ្នកតំណាងរាស្ត្រប៉ុណ្ណោះ។

**តារាងទី១** ចំនួនបេសកកម្មរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងផ្សេងៗ

| **គោលបំណង នៃការចុះបេសកកម្មនាំង ២១៨លើក ៦៨រូប** | **គណបក្សនយោបាយ** | | | **សរុបតាមគោលបំណង** |
|---|---|---|---|---|
| | ៥៨% ៤២រូប | ៨៣% ២០រូប | ២៣% ៦រូប | |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ០ | ២២ | ០ | **២២** (១០%) |
| ការសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធគំរោងនានា | ៥៥ | ២០ | ៦ | **៨១** (**៣៧**%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តុញគណបក្ស | ១៧ | ៤៤ | ៥ | **៦៦** (៣០%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៧ | ១២ | ៤ | **២៣** (១១%) |
| ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ | ១៧ | ៧ | ២ | **២៦** (១២%) |
| **សរុបជាភាគរយតាមគណបក្ស** | **៩៦** (៤៤%) | **១០៥** (៤៨%) | **១៧** (៨%) | **២១៨**(១០០%) |

ក្នុងខែសីហា ឆ្នាំ២០០៦ នេះ ខុមហ្វ្រែលសង្កេតឃើញថាតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ី មានភាពសកម្មខ្លាំងក្នុងការបង្កើនការចុះបេសកកម្មរបស់ខ្លួន ពោលគឺអ្នកតំណាងរាស្ត្រគណបក្សនេះស្ទើតែទាំងអស់ (២០រូបក្នុងចំណោម២៤រូប) បានចុះទៅមណ្ឌលរបស់រហូតដល់ទៅ១០៥លើក ដែលចំនួននេះមានការកើនឡើងស្ទើរទ្វេដង បើធៀបទៅនឹងខែកក្កដាកន្លងទៅដែលពេលនោះមានចំនួន៥៩លើកប៉ុណ្ណោះ។ ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រភាគច្រើនគឺក្នុងគោលបំណងពង្រឹងបណ្តាញគណបក្សរបស់ខ្លួនដើម្បីត្រៀមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នៅឆ្នាំ២០០៧ខាងមុខ ព្រមទាំងការចុះឃ្លាំមើល និងពន្យល់ប្រជាពលរដ្ឋអំពីការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ជាមួយគ្នានោះដែរ ការចូលរួមវេទិកាសាធារណៈរវាងអ្នកតំណាងរាស្ត្រ និង ម្ចាស់ឆ្នោត ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលនានារបស់អ្នកតំណាងរាស្ត្រគណបក្សនេះ មានការកើនឡើងច្រើន ធៀបនឹងបេសកកម្មខែមុនៗ។ ជាការគួរឱ្យកត់សំគាល់ផងដែរថា ក្នុងខែសីហានេះ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានវិលត្រលប់ចូលរួមវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាវិញ បន្ទាប់ពីមានការធ្វើពហិការអស់មួយរយៈពេលកន្លងមក។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាវិញនៅតែមានភាពសកម្មខ្លាំងដដែលក្នុងការចុះសួរសុខទុក្ខចែកអំណោយ ការកសាងសមិទ្ធិផលនានា ការចុះអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន ព្រមទាំងការពង្រឹងបណ្តាញគណបក្សរបស់ខ្លួន។ តែទោះជាយ៉ាងណា ចំនួនបេសកកម្មរបស់អ្នកតំណាងរាស្ត្រគណបក្សនេះ មិនមានការកើនឡើងគួរឱ្យកត់សំគាល់ទេ គឺប្រហាក់ប្រហែលនឹងចំនួនបេសកកម្មក្នុងខែកក្កដាកន្លងទៅប៉ុណ្ណោះ។

ខុមហ្វ្រែលសង្កេតឃើញផងដែរថា អ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចចំនួន៦រូបបានចុះបេសកកម្ម១៧លើក គឺមានការថយចុះច្រើនបើធៀបទៅនឹងចំនួនបេសកកម្មក្នុងខែកក្កដាកន្លងទៅដែលមានរហូតដល់ទៅ៣១លើក។

គួរឱ្យសោកស្តាយ ខុមហ្វ្រែលមិនបានទទួលព័ត៌ស្តីពីការចុះអន្តរាគមន៍ដើម្បីដោះស្រាយបញ្ហានានានៅក្នុងមណ្ឌល របស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចទេ។

## លិខិតអន្តរាគមន៍នានារបស់អ្នកតំណាងរាស្ត្រ

ខុមហ្វ្រែលបានទទួលព័ត៌មានថា យ៉ាងហោចណាស់ក៏មាន**អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន ៦រូប** បានចេញលិខិតអញ្ជើញចូលមកបំភ្លឺនៅរដ្ឋសភា អំពាវនាវ ស្នើចាត់វិធានការ និងបញ្ចេញមតិ **សរុប១៨ច្បាប់** ជំរាបជូននាយករដ្ឋមន្ត្រី និងស្ថាប័នដែលពាក់ព័ន្ធនានា រួមមាន:

- លិខិតអ្នកតំណាងរាស្ត្រ **សុន ឆ័យ** -ជូន**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមរយៈប្រធានរដ្ឋសភា សំណើឱ្យមានការស៊ើបអង្កេតទៅលើមន្ត្រីមន្ទីរសង្គមកិច្ចខេត្តបន្ទាយមានជ័យ ដែលធ្វើការកឹបកេងប្រាក់បៀវត្សរ៍របស់យោធិនពិការ និងយោធិនចូលនិវត្តន៍។ -ជូន**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** តាមរយៈប្រធានរដ្ឋសភា សំណើចាត់វិធានការដោះស្រាយ និងសម្រួលបញ្ហាសន្តិសុខជូនប្រជាពលរដ្ឋ នៅឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល។ -លិខិត២ច្បាប់ដោយឡែកពីគ្នា ជូន**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** : ១-លិខិតតាមរយៈប្រធានរដ្ឋសភា សំណើចាត់វិធានការស្រាវជ្រាវបញ្ឈប់សកម្មភាពនេសាទខុសច្បាប់នៅស្រុកស្អាង ខេត្តកណ្តាល និងកន្លែងដទៃទៀតឱ្យមានប្រសិទ្ធិភាព និងបំផុសឱ្យពលរដ្ឋចិញ្ចឹមកូនត្រីឡើងវិញ។ ២-លិខិតសំណើឱ្យមានការស៊ើបអង្កេត និងដាក់ទណ្ឌកម្មទៅលើមន្ត្រីរដ្ឋបាលព្រៃឈើស្រុកសំឡូត ខេត្តបាត់ដំបង ដែលសង្ស័យថាមានការជាប់ពាក់ព័ន្ធជាមួយឈ្មួញរកស៊ីកាប់ឈើខុសច្បាប់។-ជូន**នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រធានរដ្ឋសភាសំណើចាត់វិធានការស្រាវជ្រាវ និងដោះស្រាយបញ្ឈប់សកម្មភាពសាងសង់អាគារបន្ថែមនៅជុំវិញពហុកីឡាដ្ឋានជាតិអូឡាំពិករបស់ក្រុមហ៊ុនយានតាយ។ -លិខិត**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន** តាមរយៈប្រធានរដ្ឋសភា សំណើធ្វើការសម្រួលដល់ការធ្វើប័ណ្ណ

សំគាល់យានយន្តឱ្យមានភាពងាយស្រួល និងឱ្យទាន់ពេលវេលាក្នុងការយកទៅប្រើប្រាស់របស់ប្រជាពលរដ្ឋ។ -ជូន**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** តាមរយៈប្រធានរដ្ឋសភា សំណើឱ្យមានការស៊ើបអង្កេត និងដាក់ទណ្ឌកម្មទៅលើមន្ត្រីគយប្រចាំនៅមាត់ច្រកបារិត ដែលយកលុយពីក្រុមហ៊ុនទេសចរណ៍នៅពេលនាំភ្ញៀវចូលមកកំសាន្តនៅក្នុងប្រទេសកម្ពុជា។

- លិខិតអ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** -ជូន**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** តាមរយៈប្រធានរដ្ឋសភា ស្នើវិធានការករណីបាញ់ប្រហារលើប្រជាពលរដ្ឋស្លូតត្រង់នៅ ភូមិរបោះអង្កាញ់ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល។ -ជូន**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** តាមរយៈប្រធានរដ្ឋសភា សំណើចាត់វិធានការជាបន្ទាន់ចំពោះការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅតាមបណ្តាភូមិនានា។ -ជូន**អភិបាលខេត្តកណ្តាល** តាមរយៈប្រធានរដ្ឋសភា ស្នើចាត់វិធានការដោះស្រាយទំនាស់ដីបឹងរួមទំហំ២០០ហិកតា ជូនប្រជាពលរដ្ឋចំនួន២៥៨គ្រួសារ នៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។
- លិខិតអ្នកតំណាងរាស្ត្រ **កែវ រ៉េមី** -ជូន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈប្រធានរដ្ឋសភា សំណើសុំពិចារណាក្នុងការតម្លើងប្រាក់ខែជូន លោកគ្រូ-អ្នកគ្រូ តាមគំរោងថវិកាឆ្នាំ២០០៧ ខាងមុខនេះ។ -ជូន**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** តាមរយៈប្រធានរដ្ឋសភា ករណីសូមអញ្ជើញលោករដ្ឋមន្ត្រី ឬអ្នកតំណាងក្រសួងមហាផ្ទៃមកបំភ្លឺជូនសម័យប្រជុំពេញអង្គ ស្តីពីបញ្ហាជម្លៀសប្រជាពលរដ្ឋនៅភូមិសំបុកចាប មន្ទីរពេទ្យព្រះមុនីវង្ស និងសហគមន៍ដីក្រហម បញ្ហាលិចទឹកនៅក្នុងរាជធានីភ្នំពេញ និងបញ្ហារីករាលដាលនៃបនល្បែងស៊ីសង។
- លិខិតរបស់អ្នកតំណាងរាស្ត្រ **ហូរ វ៉ាន់** -ជូន**អភិបាលរាជធានីភ្នំពេញ** ស្នើអន្តរាគមន៍ដល់ប្រជាពលរដ្ឋចំនួន៣៦៨គ្រួសារដែលជួលផ្ទះគេស្នាក់នៅក្នុងសហគមន៍ដីក្រហមស្ថិតនៅសង្កាត់ទន្លេបាសាក់ដែលស្នើសុំទីជំរក។ -ជូន**ប្រធានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី** ស្នើចាត់វិធានការចំពោះបណ្តឹងរបស់ប្រជាពលរដ្ឋនៅសហគមន៍ដីក្រហមស្នើសុំតាំងទីលំនៅ និងធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង និងករណីបណ្តឹងប្រជាពលរដ្ឋនៅភូមិ១៤ សង្កាត់ទន្លេបាសាក់ ដែលត្រូវរងការឈូសឆាយពីសំណាក់ក្រុមហ៊ុនស៊ូស្រ៊ុន និងអាជ្ញាធរសាលាក្រុងភ្នំពេញ។ -ជូន**រដ្ឋមន្ត្រីក្រសួងមានមហាផ្ទៃ** ស្នើមានវិធានការលើករណីដែលអភិបាលក្រុងភ្នំពេញចាត់តាំងតែក្រុមប្រឹក្សាសង្កាត់ ខាងគណបក្សប្រជាជនកម្ពុជាឱ្យចុះផ្សព្វផ្សាយប័ណ្ណព័ត៌មាន និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកបោះឆ្នោត។
- លិខិតអ្នកតំណាងរាស្ត្រ **គួយ ប៊ុនរឿន** -ជូន**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** សំណើសុំចាត់វិធានការចំពោះអាជ្ញាធរមូលដ្ឋាននៅ ឃុំសំបួរស្រង៉ែ និងស្រុកទ្រាំង ខេត្តតាកែវដែលចាប់បង្ខំប្រជាពលរដ្ឋឱ្យស្បថដើម្បីចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា។
- លិខិតអ្នកតំណាងរាស្ត្រ **សុក ផេង** -ជូន**អភិបាលខេត្តកំពង់ធំ** តាមរយៈប្រធានរដ្ឋសភា ករណីស្នើចាត់វិធានការបង្វែរដីទំហំ១២៣ម៉ែត្រ គុណនឹង៨៧ ម៉ែត្រស្ថិតនៅក្រោយសាលាឃុំជ្រលង ភូមិទួលទំពូង ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទុកបំរើជាប្រយោជន៍សាធារណៈវិញ។ -ជូន**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សំណើមានវិធានការចំពោះការចែកប័ណ្ណព័ត៌មានដល់ប្រជាពលរដ្ឋនៅខេត្តកំពង់ធំ ព្រោះមានភាពមិនប្រក្រតីដូចជាការរើសអើង និងមានការឃឹតយ៉ាវជាដើម។

***********************************